# ថ្ងៃទី១៧ មេសា ខ្មែរក្រហមបានធ្វើអ្វី?

**( ដោយ ចាន ប្រាថ្នា )**

*ជារៀងរាល់ឆ្នាំនៅថ្ងៃទី១៧ ខែមេសា គឺមានប្រជាជនកម្ពុជាជាច្រើនតែងតែនឹកឃើញនៃការចាប់ផ្តើមនូវរបបមួយដែលជាទូទៅយើងបានហៅថា «របបខ្មែរក្រហម» ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី ដែលមានបទពិសោធការងារជា ច្រើនឆ្នាំក្នុងរឿងព្រហ្មទណ្ឌនៅតុលាការអន្តរជាតិមួយចំនួន បានហៅ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា គឺជាថ្ងៃដែល«អាយុជីវិតប្រជាជនរាប់លាននាក់ ក្លាយជាកម្មសិទ្ធិរបស់បក្សកុម្មុយនិស្តកម្ពុជា» ។*[1]

*ទោះបីរបបនេះបានកន្លងហួសជាង៣០ឆ្នាំហើយយ៉ាងណាក៏ដោយ ក៏ប្រជាជនកម្ពុជានៅតែមានការចងចាំមិនអាចបំភ្លេចបាននូវរឿងរ៉ាវដ៏សែនឈឺចាប់ និងទុក្ខសោកវេទនា ដោយសារការបែកបាក់គ្រួសារ ការតម្រូវឲ្យធ្វើការជាទម្ងន់ ភាពអត់ឃ្លាន ភាពភ័យខ្លាចជាប្រចាំ ភាពអស់សង្ឃឹមក្នុងជីវិត ភាពគ្មានទីពឹង បាត់បង់ទ្រព្យសម្បត្តិ...ដែលគាត់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលមានការសួរ នាំពីបទពិសោធរស់នៅរបស់គាត់ក្នុងរបបខ្មែរក្រហម គឺយើងតែងតែទទួលបានមកវិញនូវចម្លើយលាយឡំនឹងទឹកភ្នែកហូរមកដំណាលគ្នា ដែលតម្រូវឲ្យអ្នកសួរត្រូវបង្វែរមកនិយាយបញ្ហាផ្សេងៗវិញ ។ ប្រជាជនទូទាំងប្រទេសកម្ពុជាបានជួបរឿងរ៉ាវនេះជាច្រើនលាន់នាក់ លើកលែងតែមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមួយចំនួនប៉ុណ្ណោះ ដែលនៅតែបន្តអះអាងថាខ្លួនមិនបានដឹងអំពីបញ្ហាទាំងនេះ ។*

*នៅថ្ងៃទី២១-២៣ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបើកសវនាការលើសំណុំរឿង០០២ ដែលមានជនជាប់ចោទបួនរូប គឺ នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ(បច្ចុប្បន្នត្រូវបានបំបែកចេញពីសំណុំរឿង) ។ សវនាការនេះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញថ្លែងបើកការចោទប្រកាន់ជនជាប់ចោទទាំងបួនរូបនេះ ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងសេចក្តីថ្លែងរបស់ខ្លួន លោកជំទាវសហព្រះរាជអាជ្ញាជាតិ ជា លាង បានលើកឡើងថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ការជម្លៀសប្រជាជនដ៏គួរឲ្យរន្ធត់មួយបានកើតឡើង ។ ខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញពីលំនៅដ្ឋាន ដោយ*

---

*១-កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីបើកសេចក្តីសន្និដ្ឋានចោទប្រកាន់សំណុំរឿង០០២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ* E1/14.1 *ទំព័រទី១២ ។ អាចរកបានក្នុងគេហទំព័រ* http://www.eccc.gov.kh/document/court/16108

បោកបញ្ឆោតថា អាមេរិកកាំងនឹងមកទម្លាក់គ្រាប់បែកមកលើទីក្រុងភ្នំពេញ ។ ប្រជាជនត្រូវបានបង្ខំឲ្យចេញពីផ្ទះសម្បែង ទ្រព្យសម្បត្តិ និងខ្លះបែកបាក់សមាជិកគ្រួសារ(ដោយសារមិននៅជុំគ្នាពេលខ្មែរក្រហមជម្លៀស) ហើយធ្វើដំណើរឆ្ពោះទៅកាន់ទីជនបទឆ្ងាយៗ ។ ក្នុងរយៈពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះ នៅតាមដងវិថីនានានៃទីក្រុងភ្នំពេញ គឺពោរពេញទៅដោយហ្វូងមនុស្ស ដែលត្រូវគេបង្ខំឲ្យចាកចេញពីទីក្រុងដោយគ្មាននណាដឹងថាខ្លួននឹងត្រូវទៅទីណាឡើយ ។ បុរស ស្ត្រី កុមារ មនុស្សចាស់ជរា ជាងពីរលាននាក់ ត្រូវបានបង្ខំឲ្យចាក់ចេញដោយគ្មានការលើកលែង ។ អ្នកជំងឺ ត្រូវបានបង្ខំឲ្យចេញពីមន្ទីរពេទ្យ ស្ត្រីមានផ្ទៃពោះ អ្នកដែលទើបនឹងសម្រាលកូន ត្រូវបានគេបង្ខំឲ្យចាកចេញទាំងកណ្តាលថ្ងៃត្រង់ជាមួយនិងកូនពរក្នុងដៃ ។ លោកជិទាវ ជា លាង បានដកស្រង់ខ្លឹមសារក្នុងសៀវភៅមួយដែលបានរៀបរាប់ថា *“អ្នកជំងឺនិងអ្នករបួសរាប់ពាន់នាក់ ត្រូវបានគេបោះបង់ចោលក្នុងទីក្រុង ។ អ្នកដែលនៅមានកម្លាំង គឺខំប្រវេប្រវាទៅតាមគេ ខណៈដែលអ្នកខ្លះត្រូវបានមិត្តភក្តិជួយគ្រា និងអ្នកខ្លះទៀតត្រូវក្រុមគ្រួសារដាក់នៅលើគ្រែរុញដោយមានសេរ៉ូមភ្ជាប់ជាមួយ ដែលមើលទៅគួរឲ្យអាណិតយ៉ាងក្រៃលែង ។ ហើយអ្វីដែលលោកមិនអាចបំភ្លេចបាននោះ គឺមានបុរសម្នាក់ពិការទាំងដៃ និងជើង ខំរមៀលខ្លួននៅលើដីដូចដង្កូវដាច់ខ្លួន”* ។ លោកជិទាវ ជា លាង បានបន្តថា ប្រជាជនជាច្រើនបានស្លាប់បាត់បង់ជីវិតនៅអំឡុងពេលនៃការជម្លៀសនេះ ដោយសារជំងឺ មិនមានអាហារបរិភោគ និងការរត់ជាន់គ្នាជាដើម ។ មានសាកសពមនុស្សនៅពាសពេញផ្លូវ ហើយកងទ័ពខ្មែរក្រហមបើកឡានកិនលើមនុស្ស និងសាកសពទាំងនោះដូចសត្វធាតុ ។ យោងតាមចម្លើយរបស់សាក្សីម្នាក់ ដែលជានិរសារក្នុងកងពល២២០នៃភូមិភាគនិរតីលើកឡើងថា *“ខ្ញុំបានឃើញសាកសពច្រើនណាស់នៅតាមផ្លូវ ជាពិសេសនៅម្តុំវត្តផ្នូលចោមចៅជិតពោធិ៍ចិនតុង ។ ខ្ញុំបានឃើញផ្ទាល់ គឺកងទ័ពខ្មែរក្រហមបានបើកឡានក៏សកិនពីលើមនុស្ស...”* ។[២]

សវនាការថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឌុច បានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះសាលាដំបូងថា ខ្លួនធ្លាប់បានឮឈ្មោះ ស៊ឹម ម៉ែល ហៅ ម៉ាន ដែលជាអ្នកបានចូលរួមក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដោយផ្ទាល់ បាននិយាយប្រាប់ខ្លួនថា *“ពេលជម្លៀសហ្នឹង គេថាចេញៗ អាមេរិកកាំងមកទម្លាក់គ្រាប់បែក បើមិនចេញខ្ញុំបាញ់ បង(ឌុច) ខ្ញុំបាញ់ ។”* ។ឌុចបានបន្ថែមថា នៅពេលជម្លៀស ប្រជាជនត្រូវបានគេធ្វើការសម្រិតសម្រាំងសមាភាពមិនល្អ ហើយប្រជាជនដែលនៅសល់ ត្រូវបានគេបញ្ជូនឲ្យទៅរស់នៅតាមសហករណ៍ដើម្បីធ្វើការពិនិត្យតាមដាន និងទុកឲ្យធ្វើស្រែចម្ការ ។[៣]

---

*២-កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីបើកសេចក្តីសន្និដ្ឋានចោទប្រកាន់សំណុំរឿង០០២ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ* E1/13.1 ។ *អាចរកបានក្នុងគេហទំព័រ* http://www.eccc.gov.kh/document/court/16105

*៣-សវនាការថ្ងៃទី២០ ខែមីនាឆ្នាំ២០១២ លើសំណុំរឿង០០២ ។អាចរកបានក្នុងគេហទំព័រ* http://vimeo.com/38869698

លោកជិទាវ ដា លាង បន្ថែមថា ស្របពេលនឹងការជម្លៀសនេះដែរ ការស្រាវជ្រាវរកខ្មាំងរបស់បក្សកុម្មុយនិស្តកម្ពុជាក៏ត្រូវបានធ្វើឡើងភ្លាមៗ ដោយខ្មែរក្រហមបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅពេលប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ។ កងកម្លាំងរបស់បក្សកុម្មុយនិស្តកម្ពុជាបានតាមស្វែងរក និងសម្លាប់មន្ត្រីនិងទាហានដែលធ្វើការក្នុងរបប លន់ នល់ ។ សាក្សីម្នាក់ដែលត្រូវបានគេបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញទាំងគ្រួសារនិយាយថា នៅពេលជម្លៀសនេះ ឪពុករបស់គាត់ត្រូវបានចាប់យកទៅបាត់រហូតបន្ទាប់ពីពួកខ្មែរក្រហមរកឃើញថាគាត់ជាទាហានរបស់ លន់ នល់ ។ ការស្រាវជ្រាវរុករក និងការសម្លាប់ទាហាននិងមន្ត្រីក្នុងរបប លន់ នល់ នេះតែបន្តរហូតជាច្រើនថ្ងៃ ច្រើនសប្តាហ៍មកទៀត ។ ក្នុងការស្វែងរកនេះខ្មែរក្រហមបានប្រើប្រាស់វិធីសាស្ត្របំភាន់ភ្នែក ដោយប្រកាសឲ្យសមាជិករបស់របបចាស់រាយការណ៍ពីការងារដែលខ្លួនធ្លាប់ធ្វើ មកប្រាប់អាជ្ញាធរថ្មីរបស់ខ្លួន ដើម្បីទទួលបានការចាត់តាំងការងារនោះវិញនៅក្រោមរដ្ឋបាលថ្មី ។ ជាលទ្ធផលអ្នកទាំងអស់ដែលបានទៅរាយការណ៍នោះត្រូវបានសម្លាប់ចោល ។

ប្រជាជនដែលនៅសេសសល់ពីការជម្លៀសនេះ ត្រូវបានបក្សកុម្មុយនិស្តកម្ពុជាចាត់តាំងឲ្យនៅតាមសហករណ៍និងការដ្ឋានផ្សេងៗជាមួយប្រជាជននៅតាមមូលដ្ឋាន ។ ប្រជាជនទាំងអស់ត្រូវបានបក្សតម្រូវឲ្យធ្វើការជាទម្ងន់ ដោយមិនបានទទួលតម្លៃតបស្នងអ្វីឡើយ ពោលគឺទទួលបានតែបាយ ឬបបរបន្តិចបន្តួចប៉ុណ្ណោះ ។

តាមការផ្តល់បទសម្ភាសន៍របស់ប្រជាជនមួយចំនួន ដែលត្រូវបានបញ្ជូនឲ្យធ្វើការដោយផ្ទាល់នៅទំនប់ត្រពាំងថ្មក្នុងខេត្តបន្ទាយមានជ័យបានលើកឡើងថា ប្រជាជនម្នាក់ៗ ទាំងប្រុស ទាំងស្រី ត្រូវបានតម្រូវឲ្យ ជីក និងរែកដី ឲ្យបានពីរ ឬបីម៉ែត្រគូបក្នុងមួយថ្ងៃ ។ ប្រសិនបើធ្វើមិនហើយ នោះអាចនាំឲ្យមានការព្រមាន ឬកាត់បន្ថយរបបអាហារ ។ ចំណែកទឹកសម្រាប់បរិភោគត្រូវបានគេដឹកចែកជូនដោយមានកំណត់ ហើយនៅកន្លែងធ្វើការគឺមិនមានទឹកសម្រាប់ងូតឡើយ គឺ៣ទៅ៤ថ្ងៃទើបងូតទឹកម្តង ដោយត្រូវធ្វើដំណើរទៅទីឆ្ងាយដែលមានទឹក ។ អ្នកធ្វើការទាំងអស់ត្រូវដេកនៅកន្លែងធ្វើការរៀងៗខ្លួន ដោយអ្នកខ្លះត្រូវដេកខ្នងផ្ទាល់នឹងដីដោយសារខ្លួនមិនមានកន្ទេល មុងភួយ... ។ ប្រជាជនដែលធ្វើការនៅទីនោះបានឈឺនិងស្លាប់ជាច្រើន ដោយសារមិនអាចទ្រាំទ្របាននឹងទំហំការងារ និងលក្ខខណ្ឌក្នុងការរស់នៅបែបនេះ ។

## តើហេតុអ្វីខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

លោកសហព្រះរាជអាជ្ញាអន្តរជាតិ អេនឌ្រូ ខេលី បានលើកឡើងថា *“គោលបំណងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗ របស់ខ្មែរក្រហម គឺកើតចេញពីយុទ្ធសាស្ត្ររបស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដែលយល់ថា តំបន់ទីក្រុងគឺជាសរសៃឈាមរបស់វណ្ណៈក្បត់ វណ្ណៈខ្មាំងដែលសម្រេចថាត្រូវតែដេញចេញ និងសម្លាប់ចោល ។...ក្នុងសុន្ទរកថាខែមករា ឆ្នាំ១៩៧៧ ទៅកាន់កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជា នួន ជា បានរៀបរាប់ពីការជម្លៀសឆ្នាំ១៩៧៥ ថាជាយុទ្ធសាស្ត្ររបស់*

បក្ស គឺជាការកាត់ផ្តាច់ក្បាល និងកន្ទុយរបស់ខ្មាំង ហើយដើម្បីក្តោបក្តាប់ប្រជាជន ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ នួន ជា បានរៀបរាប់ថា មានខ្មាំងតិចតួចនៅក្នុងជនបទ ប៉ុន្តែមានខ្មាំងច្រើននៅក្នុងទីក្រុង ហើយត្រូវតែធ្វើការជម្លៀស និងបញ្ជូនពួកគេទៅជនបទដើម្បីកម្ទេចបណ្តាញពួកភ្នាក់ងារខ្មាំង ។[៤]

សវនាការថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ជនជាប់ចោទ នួន ជា បានបញ្ជាក់ជូនតុលាការថា ពាក់កណ្តាលឆ្នាំ១៩៧៤ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាបានបើកកិច្ចប្រជុំមិនពេញអង្គមួយ ដោយលើកយកបញ្ហាសំខាន់ៗមួយចំនួនមកពិភាក្សា ដើម្បីចាត់វិធានការទុកជាមុន មុនពេលរំដោះបានទីក្រុងភ្នំពេញ និងទូទាំងប្រទេស ។ ក្នុងកិច្ចប្រជុំនេះគណៈអចិន្ត្រៃយ៍បានសម្រេចជាឯកច្ឆន្ទលើ៣ចំណុច ដែលក្នុងនោះមាន១ចំណុច គឺគណៈអចិន្ត្រៃយ៍សម្រេចថា "ក្នុងករណីដែលរំដោះបានទីក្រុងភ្នំពេញ នោះយើងត្រូវជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តជាបណ្តោះអាសន្ន ដើម្បីពិនិត្យតាមស្ថានការណ៍មួយរយៈសិន ជាពិសេសពិនិត្យអំពីសកម្មភាពរបស់វៀតណាម" ។[៥] យោងតាមការលើកឡើងរបស់ នួន ជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺមិនមែនជារឿងចៃដន្យនោះទេ គឺមានការគិតទុក និងសម្រេចតាំងពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នៅពាក់កណ្តាលឆ្នាំ១៩៧៤មកម្ល៉េះ ។

ចប់

មានរឿងរ៉ាវជាច្រើនទៀតដែលគេអាចស្វែងយល់នូវអ្វី ដែលបានកើតនៅប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយចូលរកមើលតាមរយៈគេហទំព័រដូចខាងក្រោម៖

http://www.dccam.org/
http://www.cambodiatribunal.org/
http://www.eccc.gov.kh/

---

៤- ទំព័រ១៣-១៤ នៃឯកសារ E1/14.1

៥- ទំព័រ៧៣-៧៧ នៃឯកសារ E1/14.1